ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ.១៣-០១៨-០០២ ធ្ន.ក.ព.ម

ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ខេត្តកំពង់ចាម ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា

នៅថ្ងៃព្រហស្បតិ៍ ៣រោច និងថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី៤ និងទី៥ ខែមករា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជារៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា។ សន្និបាតនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកធនាគាជាតិនៃកម្ពុជាប្រមាណ៣២០នាក់ ហើយត្រូវបានធ្វើឡើងក្នុងគោលបំណងអបអរសាទរ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆ្នាំ២០១៧ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៨ សំដៅឈានទៅសម្រេចឱ្យបាននូវជោគជ័យថ្មីៗបន្ថែមទៀត។

នាឆ្នាំនេះ កម្មវិធីសន្និបាតត្រូវបានប្រារព្ធឡើងនៅខេត្តកំពង់ចាមដើម្បីផ្តល់ឱកាសជូនសមាជិកសមាជិកាអង្គសន្និបាត ជាពិសេសយុវជនបានស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជាពាក់ព័ន្ធនឹងខេត្តកំពង់ចាម ព្រមទាំងសក្តានុពលនិងការរីកចម្រើនរបស់ខេត្ត។ ខេត្តកំពង់ចាមសម្បូរដោយសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់ដូចជា ប្រាសាទហាន់ជ័យ វត្តនគរ និងអតីតរាជធានីកម្ពុជាក្នុងរជ្ជកាលព្រះស្រីជេដ្ឋាហៅស្តេចកន ដែលទ្រង់បានដាក់ឈ្មោះរាជធានីនេះថា "ក្រុងស្រឡប់ពិជ័យព្រៃនគរ"។

ទន្ទឹមនេះ សន្និបាតសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា (ស.ម.ធ) ត្រូវបានរៀបចំឡើង ហើយបានបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ (ស.ម.ធ) អាណត្តិទី៧ សម្រាប់រយៈពេល២ឆ្នាំខាងមុខ។

ទំនាក់ទំនង៖
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh